- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម **សួន សិទ្ធី** អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ជាអគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចំនួន ១៥០.០០០ ដុល្លារ ចូលរួមចំណែកកសាងសមិទ្ធផលនានា ក្នុងខេត្តកំពង់ចាម ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៤

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
  ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
  រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

## ស ំ រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ**ចំនួន ០១គ្រឿង ប្រគេនព្រះគ្រូ **ហ៊ឹម ឌុង** ព្រះចៅអធិការ *វត្ត ពោធិមាស* ដែលបានខិតខំរកបច្ច័យ ពីក្រុមគ្រួសារ នៅសហរដ្ឋអាមេរិក និង បច្ច័យផ្ទាល់ព្រះអង្គ ចំនួន ៨៥.០៥៩.៥១ ដុល្លារអាមេរិក ជួយកសាងព្រះវិហារ និង សមិទ្ធផលនានា នៅក្នុង *វត្តពោធិមាស* ឃុំទឹកជោរ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំ រេ ច**

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយសំរឹទ្ធស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ១៩រូប ដែលបានបរិច្ចាគធនធាន ផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលផ្សេងៗ ដូចជា សាលារៀន ព្រះវិហារ កុដិ ស្រះទឹក ជាដើម នៅក្នុង បរិវេណ *វត្តអង្គអណ្តែត* ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១-លោកយាយ | **ស៊ិន** | **ឡេង** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន ៤.៥៧០ ដុល្លារ |
| ២-លោក | **កែប** | **ជាន** | សប្បុរសជនខ្មែរនៅប្រទេសអូស្ត្រាលី | ទឹកប្រាក់ចំនួន ២.៥៤៣ ដុល្លារ |
| ៣-លោក | **អ៊ុក** | **ឌី** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន ២.៩៨០ ដុល្លារ |
| ៤-លោកយាយ | **តាត់** | **ឆាវគួយ** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន ២.៥២០ ដុល្លារ |
| ៥-លោក | **អ៊ុយ** | **តៀ** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ២.៨៦៥ ដុល្លារ |
| ៦-លោកតា | **ហេង** | **មុំ** | សប្បុរសជន នៅខេត្តតាកែវ | ទឹកប្រាក់ចំនួន ១.៦៣៣ ដុល្លារ |
| ៧-លោក | **ហ៊ាង** | **ខេមតិ** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ២.២៥០ ដុល្លារ |
| ៨-លោកស្រី | **ជ** | **ថែមឃ្លូ** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ២.៥២០ ដុល្លារ |
| ៩-លោក | **ឈៀក** | **ខនឃី** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ៤.២៥០ ដុល្លារ |
| ១០-លោក | **អោក** | **អ៊ី** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ៤.៦៩៨ ដុល្លារ |
| ១១-ឯកឧត្តម | **ម៉ឺន** | **ឈាវិន្ទ** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ២.៣០០ ដុល្លារ |
| ១២-លោកស្រី | **គីម** | **អាំងស្រ៊ី** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ៣.៣៦០ ដុល្លារ |
| ១៣-លោក | **ស្រ៊ុន** | **ស្រ៊ុ** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ១.៩៨០ ដុល្លារ |

/.

| | | | |
|---|---|---|---|
| ១៤-លោក | **ឃុត សារុន** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ២.៨២០ ដុល្លារ |
| ១៥-លោក | **ឃួន សុខុន** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ៣.៣៤០ ដុល្លារ |
| ១៦-លោក | **ហុក ហួ** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ១.៥៣៥ ដុល្លារ |
| ១៧-លោក | **ជាត់ មុនី** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ២.០០៨ ដុល្លារ |
| ១៨-លោក | **សោម ស៊ុន** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ១.៧១៦ ដុល្លារ |
| ១៩-លោក | **វ៉ែត ខ្លឹង** | សប្បុរសជន នៅក្រុងភ្នំពេញ | ទឹកប្រាក់ចំនួន ២.៥១០ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មករា ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៦៣៣...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

## ស ម្រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលមានសទ្ធាជ្រះថ្លាបាន បរិច្ចាគថវិកា ចូលរួមចំណែកក្នុងការកសាង សាលាឆទាន និង សមិទ្ធផលនានា នៅក្នុងភូមិកំពង់ចិន សង្កាត់ទឹកថ្លា ខណ្ឌព្រៃទប់ ក្រុងព្រះសីហនុ ដូចមានរាយនាមខាងក្រោមនេះ :-

១-ឧកញ៉ា **ឡាវ ម៉េងឃីន** ថវិកា ចំនួន ១១.០៧៥ ដុល្លារ

២-លោកជំទាវ **ជឹង សុគន្ធា** ភរិយា ឧកញ៉ា **ឡាវ ម៉េងឃីន** ថវិកា ចំនួន ១១.០១២ ដុល្លារ

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលក្រុង ព្រះសីហនុ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីពិនិត្យវាយតម្លៃការជួសជុលស្តារឡើងវិញ និង ទទួលពហុកីឡាដ្ឋានជាតិអូឡាំពិក

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/ ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ខែ កក្កដាឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញកិច្ចសន្យាស្តីពីការជួសជុលពហុកីឡាដ្ឋានអូឡាំពិកនិងការវិនិយោគសាងសង់សំណង់សណ្ឋាគារ មជ្ឈមណ្ឌលពាណិជ្ជកម្ម លើដីចំនេរនៅជុំវិញពហុកីឡាដ្ឋានជាតិអូឡាំពិក ចុះថ្ងៃទី ២៩ ឧសភា ឆ្នាំ ២០០០ រវាងរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងអប់រំ យុវជន និងកីឡា និងក្រុមហ៊ុនយានតាយសំណង់វិស្វកម្ម
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យវាយតម្លៃការជួសជុលស្តារឡើងវិញ និង ទទួលពហុកីឡាដ្ឋានជាតិអូឡាំពិកកម្ពុជាដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម អ៊ឹម សិទ្ធី | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា | ប្រធាន |
| ២-ឯកឧត្តម សេង លឹមនៅ | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣-ឯកឧត្តម ម៉ម សូផាណា | អនុរដ្ឋលេខាធិការក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៤-ឯកឧត្តម ប៊ូ ជុំសេរី | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥-លោក ជា អឿង | អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |

៦ -លោក លី សុទ្ធិ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំយុវជន និងកីឡា សមាជិក

៧ -លោក ពាស់ សាម្បាត់ចាន់ អនុប្រធាននាយកដ្ឋានអប់រំកាយនិងកីឡា សមាជិក

៨ -លោក ម្យាយ បូរិន អនុប្រធាននាយកដ្ឋានសំភារៈនិងទ្រព្យសម្បត្តិរដ្ឋ សមាជិក

៩ -លោក បឿន ចុងប៉ូ អនុប្រធាននាយកដ្ឋានសំភារៈនិងទ្រព្យសម្បត្តិរដ្ឋ សមាជិក

១០ -លោក សេង សារ៉ន អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១១ -លោក សុខ លក្ខិណា នាយករងខុទ្ទកាល័យ សាលាក្រុងភ្នំពេញ សមាជិក

១២ -លោក យស់ ឆោមណារ៉ាឌី អនុប្រធានមន្ទីរ ដនសស ក្រុងភ្នំពេញ សមាជិក

១៣ -លោក ឃៀង វិបុល ប្រធានការិយាល័យ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

១៤ -លោក ញ៉ែប ចាន់លី ប្រធានការិយាល័យ ទ្រព្យសម្បត្តិរដ្ឋ សមាជិក

១៥ -លោក នួន សំបូរ អនុប្រធានការិយាល័យ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

១៦ -លោក ជា ស៊្រុន អនុប្រធានការិ.សំណង់មន្ទីរ ដនសស ក្រុងភ្នំពេញ សមាជិក

១៧ -លោក ភ៊ូ វ៉ាន់ថន អនុប្រធានការិយាល័យ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

១៨ -លោក អំ ប៊ុនលី ប្រធានការិយាល័យរៀបចំ ដនសស ខ័ណ្ឌ ៧មករា សមាជិក

១៩ -លោក ព្រុំ ដារ៉ា មន្ត្រីនាយកដ្ឋានសំភារៈ និង ទ្រព្យសម្បត្តិរដ្ឋ សមាជិក

**ប្រការ២ :** គណៈកម្មការនេះមានភារកិច្ចត្រួតពិនិត្យ រាល់ការងារជួសជុលឡើងវិញហេដ្ឋារចនាសម្ព័ន្ធពហុកីឡាដ្ឋានជាតិអូឡាំពិក របស់ក្រុមហ៊ុនយានពាយសំណង់វិស្វកម្ម សមស្របទៅនឹងកិច្ចសន្យា ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០០ និងសៀវភៅបន្ទុក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ ដើម្បីទទួលពហុកីឡាដ្ឋានជាតិអូឡាំពិកមកប្រើប្រាស់ ។

**ប្រការ៣ :** គណៈកម្មការនេះមានសិទ្ធិចាត់ចែងមន្ត្រីរាជការក្រោមឱវាទរៀង១ខ្លួន អោយជួយក្នុងការងារ និងមានសិទ្ធិបង្កើតក្រុមការងារមួយចំនួន ។

**ប្រការ៤ :** សមាសភាពគណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ សាលាក្រុងភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ មករា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចំលងជូនៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៧ . សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការសម្របសម្រួលគម្រោងស្ថាបនាផ្លូវជាតិលេខ ១ (ក្បាលថ្នល់-អ្នកលឿង) និងគម្រោងស្ថាបនាស្ពានឆ្លងកាត់ទន្លេមេគង្គ (អ្នកលឿង)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការសម្របសម្រួលគម្រោងស្ថាបនាផ្លូវជាតិលេខ ១ (ក្បាលថ្នល់-អ្នកលឿង) និងគម្រោងស្ថាបនាស្ពានឆ្លងកាត់ទន្លេមេគង្គ (អ្នកលឿង) ដែលមានសមាសភាព ដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- ឯកឧត្តម | **អ៊ឹក ចាន់** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- ឯកឧត្តម | **ញាណ ឡេង** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- ឯកឧត្តម | **វង្សី វិស្សុត** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ឯកឧត្តម | **ឆាយ សារ៉េត** | អភិបាល ខេត្តព្រៃវែង | សមាជិក |
| ៦- លោក | **ឃីម បូរ** | អភិបាលរងទី ១ ខេត្តកណ្តាល | សមាជិក |
| ៧- លោក | **ឡេង សុជា** | អគ្គលេខាធិការរង អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | សមាជិក |

| | | | |
|---|---|---|---|
| ៨- លោក | **តូច ចាន់កុសល** | អគ្គនាយករងទី ១ អគ្គនាយកដ្ឋានសាធារណការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៩- លោក | **លឹម ស៊ីដេនីន** | នាយក នាយកដ្ឋានផ្លូវថ្នល់ អគ្គនាយកដ្ឋានសាធារណការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- លោក | **ឃុយ ហៀង** | ប្រធាននាយកដ្ឋានគមនាគមន៍ និងប្រៃសណីយ៍ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១- លោក | **ចាន់ សុនី** | ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២- លោក | **នារ ជុប** | ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រសួងបរិស្ថាន | សមាជិក |
| ១៣- បណ្ឌិត | **ជា វ៉ាន់ដេត** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៤- លោក | **តី សុនាត់** | នាយករង មជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស សាធារណការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៥- លោក | **មាស សឿន** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកណ្ដាល | សមាជិក |

**ប្រការ២ :** គណៈកម្មការមានភារកិច្ចសហការជាមួយស្ថានទូតជប៉ុន JICA និងក្រុមហ៊ុនជប៉ុន ក្នុងការដោះស្រាយលើផលប៉ះពាល់លំនៅដ្ឋាន ដីធ្លីប្រជាជន និងពិនិត្យដោះស្រាយបញ្ហាផ្សេងៗ សម្រាប់គម្រោងដែលអាចនឹងមាន ក្នុងពេលក្រុមហ៊ុនអនុវត្តគម្រោង ។

**ប្រការ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*បម្លងជូន :*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចចែងក្នុងប្រការ ៣*
- *ឯកសារ-កាលប្បវត្តិ*

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ០៣ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់ នូវការឆ្លងរាលដាល នៃជំងឺផ្ដាសាយបក្សី
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសភាពការណ៍ចាំបាច់របស់រដ្ឋាភិបាល

## ស ម្រេ ច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺផ្ដាសាយបក្សី ។

គណៈកម្មការនេះមានសមាសភាព ដូចខាងក្រោម ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាប្រធាន |
| ២- តំណាងក្រសួងសុខាភិបាល | អនុប្រធាន |
| ៣- តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤- តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

៧- តំណាងទីចាត់ការគយ និង រដ្ឋាករ សមាជិក

៨- អភិបាលខេត្តក្រុងពាក់ព័ន្ធ សមាជិក

៩- ប្រធាននាយកដ្ឋានផលិតកម្ម និង បសុពេទ្យ លេខាធិការ

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចទទួលខុសត្រូវរួម លើការណែនាំអនុវត្តទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺផ្តាសាយបក្សីសហការជាមួយអង្គការ FAO WHO OIE អង្គការជាតិ និងអន្តរជាតិផ្សេងទៀតតាមការចាំបាច់ និង ធ្វើរបាយការណ៍លំអិតជូនរាជរដ្ឋាភិបាលអំពីលទ្ធផលការងារដែលអនុវត្តបាន និង ស្នើសុំយោបល់សំរេចពីរាជរដ្ឋាភិបាលក្នុងករណីមានការចាំបាច់ ។

**ប្រការ ៣ :** សមាជិកគណៈកម្មការអន្តរក្រសួងនេះត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិរៀបចំលេខាធិការដ្ឋានមួយដើម្បីជំនួយការងារដែលមានទីតាំង និងសមាសភាពកំណត់ ដោយឯកឧត្តមប្រធានគណៈកម្មការ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និង សមាសភាពដូចចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាដូចតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

*-ដូចប្រការ ៤*

*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៧៦ សហវ.ប្រក

# ប្រកាស

ស្តីពី

## ការបង្កើតសាខាពន្ធដារក្រុងប៉ៃលិន

***********

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួង និង រដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ប្រកាសលេខ ០៦៣ សហវ/ប្រក/ប ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៨ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបង្កើតស្នាក់ការពន្ធដារក្រុងប៉ៃលិន
- បានឃើញ ការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមលិខិតស្នើរបស់ប្រធាននាយកដ្ឋានពន្ធដារ

## សម្រេច:

**ប្រការ១:** បង្កើតសាខាពន្ធដារក្រុងប៉ៃលិន ( ថ្នាក់ស្មើការិយាល័យនៅថ្នាក់កណ្តាល ) ដែលមានភារកិច្ចធ្វើជាសេនាធិការឱ្យនាយកដ្ឋានពន្ធដារ លើការងារគ្រប់គ្រងប្រមូលពន្ធ ។

**ប្រការ២:** រចនាសម្ព័ន្ធរបស់សាខាពន្ធដារក្រុងប៉ៃលិន រួមមាន ០៤ ផ្នែក ( ថ្នាក់ស្មើការិយាល័យនៅខេត្ត-ក្រុង ) និង ស្នាក់ការពន្ធដារនៅតាមខ័ណ្ឌ ( ថ្នាក់ស្មើការិយាល័យនៅខេត្ត-ក្រុង ) :

**ក- បណ្តាផ្នែក :**

១- ផ្នែកបុគ្គលិក-រដ្ឋបាល និង ហិរញ្ញវត្ថុ

២- ផ្នែកវិវាទ

៣- ផ្នែកប្រថាប់ត្រា-តែមប្រ៊ី

៤ ប៉ុស្តិ៍គណនេយ្យដើមខ្សែ ( ថ្នាក់ស្មើការិយាល័យនៅខេត្ត-ក្រុង )

**ខ- បណ្តាស្នាក់ការ :**

១- ស្នាក់ការពន្ធដារខ័ណ្ឌប៉ៃលិន

២- ស្នាក់ការពន្ធដារខ័ណ្ឌសាលាក្រៅ

- សាខាពន្ធដារដឹកនាំដោយប្រធានមួយរូប និង អនុប្រធានជំនួយការ
- ផ្នែក និង ស្នាក់ការពន្ធដារដឹកនាំដោយប្រធានមួយរូប និង អនុប្រធានជំនួយការ ។

**ប្រការ៣:** សាខាពន្ធដារក្រុងប៉ៃលិន មានសិទ្ធិប្រើប្រាស់ត្រាមួយដោយឡែក ផ្តល់ជូនដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ប្រើប្រាស់ក្នុងការងារពន្ធដារ ។

**ប្រការ៤:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និង អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មករា ឆ្នាំ២០០៤

**គាត ឈន់**

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាក្រុងប៉ៃលិន

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៤
- កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៣៧ សហវ.៣៥

# ប្រកាស

## ស្តីពី

## ការបង្កើតស្នាក់ការពន្ធដារស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

***********

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួង និង រដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ប្រកាសលេខ ០១៤ ប្រក/កហវ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៩១ របស់ក្រសួងហិរញ្ញវត្ថុ ស្តីពីការបង្កើតសាខាពន្ធដារខេត្តបន្ទាយមានជ័យ
- បានឃើញ ប្រកាសលេខ ២៩០ សហវ/ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការទទួលស្គាល់មន្ត្រីរាជការពន្ធដាររបស់ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ មកក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមលិខិតស្នើរបស់ប្រធាននាយកដ្ឋានពន្ធដារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone 855-23-724 664 Fax 855-23-427 798

## សំរេច:

**ប្រការ១:** បង្កើតស្នាក់ការពន្ធដារស្រុកម៉ាឡៃ ( ថ្នាក់ស្មើការិយាល័យនៅខេត្ត-ក្រុង ) ស្ថិតក្នុងសាខាពន្ធដារខេត្តបន្ទាយមានជ័យ ។

**ប្រការ២:** ស្នាក់ការពន្ធដារនេះ មានតួនាទី ភារកិច្ច អនុវត្តការគ្រប់គ្រងប្រមូលពន្ធស្របតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ។

**ប្រការ៣:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និង អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] ខែ មករា ឆ្នាំ២០០៤

**គាត ឈន់**

**ចម្លងជូន:**

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្តបន្ទាយមានជ័យ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៣
- កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ : ០០៦ សហវ

រាជធានី ភ្នំពេញ, ថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៤

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតនិងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ ខេត្ត ឧត្តរមានជ័យ

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យ លេខ ០៤/អនក្រ/បក/១៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៦៤/អនក្រ/បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០១
- បានឃើញ ច្បាប់ស្តីពីពន្ធលើទំនិញ នាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦-០៧-១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ
- យោងចំណារឯកភាព របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៣លើលិខិតលេខ ៥៩៨៧ សហវ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## <u>សំរេច</u>

<u>ប្រការ ១</u>: ក- បង្កើត និងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ ខេត្ត ឧត្តរមានជ័យ ថ្នាក់ប្រហាក់ប្រហែលមន្ទីរនានាជុំវិញខេត្ត ស្ថិតក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ ។

ខ- សាខាគយនិងរដ្ឋាករ ខេត្ត ឧត្តរមានជ័យ មានភារកិច្ច សិទ្ធិ និង ទីតាំងដូចខាងក្រោម ÷

សាខាគយ-រដ្ឋាករ ខេត្ត ឧត្តរមានជ័យ បោះទីតាំងនៅ ទីរួមខេត្ត ឧត្តរមានជ័យមានភារកិច្ចគ្រប់គ្រងរាល់ ទីតាំងគយនិងរដ្ឋាករទាំងអស់ដែលមាននៅក្នុងខេត្តឧត្តរមានជ័យ : ទីស្នាក់ការគយ និងរដ្ឋាករអូរស្មាច់, ទីស្នាក់ការគយនិងរដ្ឋាករជាំ ឬ សង្គុំ (ស្រុក អន្លង់វែង) និង ទីស្នាក់ការគយនិងរដ្ឋាករ ព្រះប្រឡាយ (ស្រុកត្រពាំងប្រាសាទ) ។ ដោយឡែកសាខាគយនិងរដ្ឋាករនេះក៏មានភារកិច្ចបង្កើតនិងប្រើប្រាស់កម្លាំងចល័ត សហការជាមួយអាជ្ញាធរ មានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសគេចពន្ធនានាក្នុងភូមិសាស្ត្រនៃខេត្ត ឧត្តរមានជ័យ ទាំងមូល ។

គ- ក្បាលម៉ាស៊ីនរបស់សាខាគយនិងរដ្ឋាករ ត្រូវបែងចែកជាផ្នែកគឺ ÷

១- ផ្នែក រដ្ឋបាល
២- ផ្នែក ត្រួតពិនិត្យ
៣- ផ្នែក គណនេយ្យ
៤- ផ្នែកប្រឆាំងនិងបង្ក្រាបអំពើរត់ពន្ធ
៥- ផ្នែក បច្ចេកទេសគយ
៦- ផ្នែក វិវាទនិងច្បាប់

<u>ប្រការ ២</u> សាខាគយនិងរដ្ឋាករនេះ មាន ប្រធាន មួយរូបដឹកនាំ និង អនុប្រធានមួយចំនួនជាជំនួយការ ។
ប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង ប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករនិងមានឋានៈស្មើនឹងអនុប្រធាន មន្ទីរនានាជុំវិញខេត្ត ក្រុង ។
អនុប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង អនុប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករ និងមានឋានៈស្មើនឹង ប្រធានការិយាល័យ នៃមន្ទីរនានាជុំវិញខេត្ត ក្រុង ។

<u>ប្រការ ៣</u> ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និង សាខាគយនិងរដ្ឋាករ ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវមានភារកិច្ចអនុវត្តតាមសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

គាត ឈន់

<u>កន្លែងទទួល :</u>
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
« ដើម្បីជូនជ្រាប »
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អភិបាលខេត្ត ឧត្ដរមានជ័យ
« ដើម្បីសហការអនុវត្ត »
- ដូចប្រការ ៣ « ដើម្បីអនុវត្ត »
- កាលប្បវត្តិ - ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ: ០០៦ សហវ.......

រាជធានី ភ្នំពេញ, ថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០០៤

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើត និងដាក់ឱ្យដំណើរការ ទីស្នាក់ការគយនិងរដ្ឋាករថ្មី
## នៅ ខេត្ត កំពង់ចាម

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យ លេខ ០៤/អនក្រ/បក/១៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៦៤/អនក្រ/បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០១
- បានឃើញ ច្បាប់ស្តីពីពន្ធលើទំនិញ នាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦-០៧-១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ
- យោងចំណារឯកភាព របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៣លើលិខិតលេខ ៩៩៨៧ សហវ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## <u>សំរេច</u>

<u>ប្រការ ១:</u> បង្កើត ទីស្នាក់ការគយនិងរដ្ឋាករ ត្នោត នៅខេត្ត កំពង់ចាម ថ្នាក់ស្មើ ការិយាល័យ នៃមន្ទីរនានា ខេត្ត - ក្រុង ស្ថិតក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ មានដូចខាងក្រោម ÷

- ទីស្នាក់ការគយ និងរដ្ឋាករ ត្នោត ក្នុងភូមិសាស្ត្រ ភូមិ អន្លង់ក្រេះ ឃុំ កក់ ស្រុក ពញាក្រែក ខេត្ត កំពង់ចាម ។
- តួ នាទី ភារកិច្ច ស្ថិតក្នុងវចនាសម្ព័ន្ធ របស់សាខាគយនិងរដ្ឋាករខេត្តកំពង់ចាម ។

<u>**ប្រការ ២**</u> ទីស្នាក់ការគយនិងរដ្ឋាករ មានសិទ្ធិ និងភារកិច្ចស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធ គ្រប់គ្រងទំនិញនាំចេញ នាំចូល និងប្រមូលពន្ធតាមច្បាប់ និងលិខិតបទដ្ឋាននានា ដែលរដ្ឋបានផ្តល់សិទ្ធិអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា ។

<u>**ប្រការ ៣**</u> ទីស្នាក់ការគយនិងរដ្ឋាករ ត្រូវមានប្រធានមួយរូបដឹកនាំ និងមានអនុប្រធានមួយចំនួន ជាជំនួយការ ។

- ប្រធាន ទីស្នាក់ការគយនិងរដ្ឋាករមានឋានៈ ស្មើនឹង ប្រធាន ការិយាល័យនានាជុំវិញខេត្ត- ក្រុង និងឋានៈស្មើនឹង អនុប្រធានការិយាល័យ នៅទីចាត់ការគយនិងរដ្ឋាករ ។
- អនុប្រធាន ទីស្នាក់ការគយនិងរដ្ឋាករមានឋានៈស្មើនឹង អនុប្រធានការិយាល័យនានាជុំវិញខេត្ត- ក្រុង ។

<u>**ប្រការ ៤**</u>: ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និង បណ្តាសាខាគយនិងរដ្ឋាករ ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវមានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

<u>**កន្លែងទទួល :**</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  « ដើម្បីជូនជ្រាប »
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អភិបាលខេត្ត កំពង់ចាម
  « ដើម្បីសហការអនុវត្ត »
- ដូចប្រការ ៤ « ដើម្បីអនុវត្ត »
- កាលប្បវត្តិ - ឯកសារ

**គាត ឈន់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ : ០០៧២ សហវ

រាជធានី ភ្នំពេញ, ថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០០៤

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតនិងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ
## ខេត្ត កំពង់ធំ

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យ លេខ ០៤/អនក្រ/បក/១៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៦៤/អនក្រ/បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០១
- បានឃើញ ច្បាប់ស្តីពីពន្ធលើទំនិញ នាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦-០៧-១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ
- យោងចំណារឯកភាព របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៣លើលិខិតលេខ ៩៩៨៧ សហវ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## <u>សំរេច</u>

<u>ប្រការ ១</u>: ក- បង្កើត និងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ ខេត្ត កំពង់ធំ ថ្នាក់ប្រហាក់ប្រហែលមន្ទីរមានាជុំវិញខេត្ត ស្ថិតក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ ។

ខ- សាខាគយនិងរដ្ឋាករ ខេត្ត កំពង់ធំ មានភារកិច្ច សិទ្ធិ និង ទីតាំងដូចខាងក្រោម ÷

- សាខាគយ-រដ្ឋាករខេត្តកំពង់ធំ បោះទីតាំងនៅទីរួមខេត្ត កំពង់ធំ មានភារកិច្ចគ្រប់គ្រងរាល់ទីតាំងគយនិងរដ្ឋាករទាំងអស់ដែលមាននៅក្នុងខេត្តកំពង់ធំ : មានភារកិច្ចគ្រប់គ្រងបញ្ជាកម្លាំងចល័តក្នុងខេត្តកំពង់ធំ និង ខេត្តព្រះវិហារ ទប់ស្កាត់ទំនិញល្មើសឆ្លងកាត់ពីខេត្តបន្ទាយមានជ័យនិងសៀមរាប ។

គ- ក្បាលម៉ាស៊ីនរបស់សាខាគយនិងរដ្ឋាករ ត្រូវបែងចែកជាផ្នែកគឺ ÷

១- ផ្នែក រដ្ឋបាល
២- ផ្នែក ត្រួតពិនិត្យ
៣- ផ្នែក គណនេយ្យ
៤- ផ្នែកប្រឆាំងនិងបង្ក្រាបអំពើរត់ពន្ធ
៥- ផ្នែក បច្ចេកទេសគយ
៦- ផ្នែក វិវាទនិងច្បាប់

**ប្រការ ២** សាខាគយនិងរដ្ឋាករនេះ មាន ប្រធាន មួយរូបដឹកនាំ និង អនុប្រធានមួយចំនួនជាជំនួយការ ។
ប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង ប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករនិងមានឋានៈស្មើនឹងអនុប្រធាន មន្ទីរនានាជុំវិញខេត្ត ក្រុង ។
អនុប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង អនុប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករ និងមានឋានៈស្មើនឹង ប្រធានការិយាល័យ នៃមន្ទីរនានាជុំវិញខេត្ត ក្រុង ។

**ប្រការ ៣** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និង សាខាគយនិងរដ្ឋាករ ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវមានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

គាត ឈន់

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  « ដើម្បីជូនជ្រាប »
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អភិបាលខេត្ត កំពង់ធំ
  « ដើម្បីសហការអនុវត្ត »
- ដូចប្រការ ៣ « ដើម្បីអនុវត្ត »
- កាលប្បវត្តិ - ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ០០៥ សហវ.....

រាជធានី ភ្នំពេញ,ថ្ងៃទី ១៥ ខែមករាឆ្នាំ ២០០៤

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតនិងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ ខេត្ត ក្រចេះ

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យ លេខ ០៤/អនក្រ/បក/១៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៦៤/អនក្រ/បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០១
- បានឃើញ ច្បាប់ស្តីពីពន្ធលើទំនិញ នាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦-០៧-១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ
- យោងចំណារឯកភាព របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៣លើលិខិតលេខ ៥៩៨៧ សហវ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សំរេច

ប្រការ ១: ក- បង្កើត និងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ ខេត្ត ក្រចេះ ថ្នាក់ប្រហាក់ប្រហែលមន្ទីរនានាជុំវិញខេត្ត ស្ថិតក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ ។

ខ- សាខាគយនិងរដ្ឋាករ ខេត្ត ក្រចេះ មានភារកិច្ច សិទ្ធិ និង ទីតាំងដូចខាងក្រោម ÷

- សាខាគយ-រដ្ឋាករខេត្ត ក្រចេះ បោះទីតាំងនៅទីរួមខេត្ត ក្រចេះ មានភារកិច្ចគ្រប់គ្រងរាល់ទីតាំងគយនិងរដ្ឋាករទាំងអស់ដែលមាននៅក្នុងខេត្តក្រចេះ : ទីស្នាក់ការគយនិងរដ្ឋាករស្នួល ,ទីស្នាក់ការគយនិងរដ្ឋាករជ័យឃ្លាំង និង ទីស្នាក់ការគយនិងរដ្ឋាករ ត្រពាំងស្រែ ។ ដោយឡែកសាខាគយនិងរដ្ឋាករនេះក៏មានភារកិច្ចបង្កើតនិងប្រើប្រាស់កម្លាំងចល័ត សហការជាមួយអាជ្ញាធរ មានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសគេចពន្ធនានាក្នុងភូមិសាស្ត្រនៃខេត្តក្រចេះទាំងមូល ។

គ- ក្បាលម៉ាស៊ីនរបស់សាខាគយនិងរដ្ឋាករ ត្រូវបែងចែកជាផ្នែកគឺ ÷

១- ផ្នែក រដ្ឋបាល
២- ផ្នែក ត្រួតពិនិត្យ
៣- ផ្នែក គណនេយ្យ
៤- ផ្នែកប្រឆាំងនិងបង្ក្រាបអំពើរត់ពន្ធ
៥- ផ្នែក បច្ចេកទេសគយ
៦- ផ្នែក វិវាទនិងច្បាប់

**ប្រការ ២** សាខាគយនិងរដ្ឋាករនេះ មាន ប្រធាន មួយរូបដឹកនាំ និង អនុប្រធានមួយចំនួនជាជំនួយការ ។
ប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង ប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករនិងមានឋានៈស្មើនឹងអនុប្រធាន មន្ទីរនានាជុំវិញខេត្ត ក្រុង ។
អនុប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង អនុប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករ និងមានឋានៈស្មើនឹង ប្រធានការិយាល័យ នៃមន្ទីរនានាជុំវិញខេត្ត ក្រុង ។

**ប្រការ ៣** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និង សាខាគយនិងរដ្ឋាករ ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវមានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  « ដើម្បីជូនជ្រាប »
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អភិបាលខេត្ត ក្រចេះ
  « ដើម្បីសហការអនុវត្ត »
- ដូចប្រការ ៣ « ដើម្បីអនុវត្ត »
- កាលប្បវត្តិ - ឯកសារ

គាត ឈន់